# ក្រមសីលធម៌

# សម្រាប់មន្ត្រី

# ប្រតិបត្តិច្បាប់

# ក្រមសីលធម៌សំរាប់ មន្ត្រីប្រតិបត្តិច្បាប់

# Code of Conduct for Law Enforcement Officials



# ក្រមសីលធម៌សំរាប់មន្ត្រីប្រតិបត្តិច្បាប់
# Code of Conduct for Law Enforcement Officials

*អនុម័តដោយសេចក្តីសំរេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ ៣៤/១៦៩ ចុះថ្ងៃ ទី១៧ ខែធ្នូ ឆ្នាំ១៩៧៩ ។*
*Adopted by General Assembly resolution 34/169 of 17 December 1979.*

**មាត្រា ១**

ក្នុងការបំរើសហគមន៍ និងក្នុងការការពារមនុស្សគ្រប់រូបកុំឱ្យប្រព្រឹត្តខុសច្បាប់ មន្ត្រីប្រតិបត្តិច្បាប់ត្រូវបំពេញភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមច្បាប់គ្រប់ពេលវេលា ដោយមានការទទួលខុសត្រូវខ្ពស់តាមវិជ្ជាជីវៈរបស់ខ្លួន ។

***អត្ថាធិប្បាយ :***

ក- ពាក្យថា " មន្ត្រីប្រតិបត្តិច្បាប់ " សំដៅដល់មន្ត្រីទាំងអស់ ទោះជាត្រូវតែងតាំង ឬត្រូវជ្រើសតាំងក្តី ឱ្យតែប្រើប្រាស់អំណាចនគរបាល ជាពិសេសអំណាចក្នុងការចាប់ខ្លួន ឬឃុំខ្លួន ។

ខ- នៅក្នុងប្រទេសទាំងឡាយ ដែលអាជ្ញាធរយោធាប្រើប្រាស់អំណាចនគរបាល ទោះជាមាន ឬគ្មានឯកសណ្ឋានក្តី ឬដោយកំលាំងសន្តិសុខរបស់រដ្ឋ មន្ត្រីទាំងឡាយដែលបំរើការងារនោះត្រូវចាត់ចូលក្នុងនិយមន័យនៃមន្ត្រីប្រតិបត្តិច្បាប់ ។

គ- ការផ្តល់សេវាបំរើសហគមន៍ គឺមានគោលដៅដាក់បញ្ចូលជាពិសេសនូវសេវាជំនួយឧបត្ថម្ភដល់សមាជិកសហគមន៍ទាំងនោះ ហើយដោយសារតែមូលហេតុផ្ទាល់ខ្លួន មូលហេតុសេដ្ឋកិច្ច មូលហេតុសង្គមកិច្ច ឬភាពបន្ទាន់បង្ខំផ្សេងទៀត ទើបពួកគេត្រូវការជំនួយទាំងនេះជាបន្ទាន់ ។

ឃ- បញ្ញត្តិនេះមានគោលដៅធ្វើការទប់ស្កាត់ មិនត្រឹមតែអំពើហឹង្សា អំពើសាហាវព្រៃផ្សៃ និងការធ្វើទុក្ខទោសដល់អ្នកដទៃប៉ុណ្ណោះទេ តែថែមទាំងធ្វើការទប់ស្កាត់ចំពោះអំពើល្មើសផ្សេងទៀត ដែលមានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌ ។ បញ្ញត្តិនេះក៏ អនុវត្តចំពោះជនទាំងឡាយដែលមិនអាចទទួលខុសត្រូវផ្នែកព្រហ្មទ័ណ្ឌផងដែរ ។

**មាត្រា ២**

ក្នុងការបំពេញភារកិច្ចរបស់ខ្លួន មន្ត្រីប្រតិបត្តិច្បាប់ត្រូវគោរព និងការពារសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ រក្សា និងលើកស្ទួយសិទ្ធិមនុស្សរបស់ជនគ្រប់រូប ។

***អត្ថាធិប្បាយ :***

ក- សិទ្ធិមនុស្សដូចមានចែងខាងលើ ត្រូវបានទទួលស្គាល់ និងការពារដោយច្បាប់ជាតិ និងច្បាប់អន្តរជាតិ ។ ក្នុងនោះមានលិខិតុបករណ៍ពាក់ព័ន្ធមួយចំនួន ដូចជា សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សេចក្តីប្រកាសស្តីពីការពារជនគ្រប់រូប កុំឱ្យមានការធ្វើទារុណកម្ម ឬការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់ នៃការរើសអើងពូជសាសន៍ អនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាប និងផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មនៃពួកអាប៉ាថេដ អនុសញ្ញាអន្តរជាតិស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ បញ្ញត្តិជាបទដ្ឋានអប្បបរមា សំរាប់គ្រប់គ្រងអ្នកទោស ហើយនិងមាន អនុសញ្ញាទីក្រុងវីយែនស្តីពីទំនាក់ទំនងកុងស៊ុល ។

ខ- សេចក្តីអត្ថាធិប្បាយថ្នាក់ជាតិលើបញ្ញត្តិនេះ គួរបញ្ជាក់ថាជាបទបញ្ញត្តិថ្នាក់ជាតិ ឬថ្នាក់តំបន់ដែលបានទទួលស្គាល់ និងការពារសិទ្ធិទាំងនេះ ។

## មាត្រា ៣

មន្ត្រីប្រតិបត្តិច្បាប់អាចប្រើប្រាស់កំលាំងបាន តែក្នុងកាលៈទេសៈណាដែលចាំបាច់បំផុត និងស្ថិតនៅក្នុងវង្វង់នៃការបំពេញភារកិច្ចរបស់ខ្លួនតែប៉ុណ្ណោះ ។

***អត្ថាធិប្បាយ :***

ក- បញ្ញត្តិនេះបញ្ជាក់ថា ការប្រើប្រាស់កំលាំងដោយមន្ត្រីប្រតិបត្តិច្បាប់អាចមានការលើកលែង មានន័យថា មន្ត្រីប្រតិបត្តិច្បាប់ត្រូវបានអនុញ្ញាតិឱ្យប្រើប្រាស់កំលាំងតាមការចាំបាច់ និងសមហេតុផល ដើម្បីទប់ស្កាត់បទល្មើស ឬដើម្បីធ្វើឱ្យមានប្រសិទ្ធិភាព ឬដើម្បីជួយក្នុងការចាប់ខ្លួនជនល្មើស ឬជនសង្ស័យតាមច្បាប់ ប៉ុន្តែមិនត្រូវប្រើកំលាំងហួសហេតុឡើយ ។

ខ- តាមធម្មតា ច្បាប់ជាតិនៃប្រទេសនីមួយៗ បានដាក់កំហិតយ៉ាងតឹងតែងដល់មន្ត្រីប្រតិបត្តិច្បាប់ក្នុងការប្រើប្រាស់កំលាំងនេះ ដោយអនុលោមតាមគោលការណ៍សមាមាត្រ ។ គេក៏ត្រូវយល់ដែរថា គេត្រូវគោរពតាមគោលការណ៍ជាតិស្តីពីសមាមាត្រក្នុងការបកស្រាយបញ្ញត្តិនេះ ។ ទោះជាក្នុងករណីណាក៏ដោយ មិនត្រូវធ្វើការបកស្រាយ

បញ្ញត្តិនេះ ដើម្បីអនុញ្ញាតឱ្យប្រើប្រាស់កំលាំង ដែលមិនសមាមាត្រ ដើម្បីសំរេចបាននូវគោលដៅស្របច្បាប់ណាមួយឡើយ ។

គ- ការប្រើប្រាស់អាវុធត្រូវបានគេចាត់ទុកថា ជាវិធានការមួយដែលខ្លាំងក្លាបំផុត ។ មន្ត្រីប្រតិបត្តិច្បាប់ត្រូវខំជៀសវាងការប្រើប្រាស់អាវុធ ជាពិសេសទៅលើអនីតិជន ។ ជាទូទៅ ការប្រើអាវុធត្រូវហាមឃាត់ លើកលែងតែក្នុងករណីណាដែលជនល្មើសតដៃ ឬបង្កគ្រោះថ្នាក់ដល់ជីវិតអ្នកដទៃ ឬក្នុងកាលៈទេសៈណាដែលការចាត់វិធានការមិនមានកំលាំងគ្រប់គ្រាន់ ដើម្បីបញ្ឈប់ ឬចាប់ខ្លួនជនល្មើស ។ ពេលណាដែលមានការបាញ់កាំភ្លើងត្រូវរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ចភ្លាម ។

## មាត្រា ៤

ចំពោះរឿងរ៉ាវទាំងឡាយមានចរិតជាការសំងាត់ ហើយដែលឋិតនៅក្នុងដៃមន្ត្រីប្រតិបត្តិច្បាប់ត្រូវតែរក្សាទុកជាសំងាត់ លើកលែងតែត្រូវបំពេញភារកិច្ច ឬត្រូវស្វែងរកយុត្តិធម៌ ។

***អត្ថាធិប្បាយ :***

តាមប្រភេទការងាររបស់ខ្លួន មន្ត្រីប្រតិបត្តិច្បាប់ ទទួលពត៌មាននានា ដែលអាចមានការទាក់ទងដល់ជីវិតរស់នៅផ្ទាល់ខ្លួន ឬដែលអាចបណ្តាលឱ្យខូចខាតដល់ប្រយោជន៍ជាសក្តានុពល ឬជាពិសេសប៉ះពាល់ដល់កិត្តិយសអ្នកដទៃ ។ មន្ត្រីប្រតិបត្តិច្បាប់ត្រូវប្រុងប្រយ័ត្នបំផុតក្នុងការរក្សា និងការប្រើប្រាស់ពត៌មាននេះ ហើយព័ត៌មាននេះអាចលាតត្រដាងបានសំរាប់តែការបំពេញភារកិច្ច ស្វែងរកយុត្តិធម៌តែប៉ុណ្ណោះ ។ ការយករឿងអាថ៌កំបាំងរបស់អ្នកដទៃ ទៅលាតត្រដាងក្នុងគោលបំណងអ្វីផ្សេងពីនេះ ត្រូវហាមឃាត់ជាដាច់ខាត ព្រោះនេះជាការមិនសមរម្យទាល់តែសោះ ។

## មាត្រា ៥

មន្ត្រីប្រតិបត្តិច្បាប់គ្រប់រូបមិនអាចប្រព្រឹត្ត ធ្វើការញុះញង់ ឬបណ្តោយឱ្យមានការធ្វើទារុណកម្ម និងការប្រព្រឹត្តឃោរឃៅ អមនុស្សធម៌ ឬទណ្ឌកម្មឯទៀតឡើយ ។ ក្រៅពីនេះ មន្ត្រីប្រតិបត្តិច្បាប់មិនត្រូវដាក់បញ្ជាបែបជាចៅហ្វាយនាយផ្សេងៗ ឬមានការលើកលែងចំពោះករណីមួយចំនួនដូចជា ក្នុងស្ថានភាពដែលមានសង្គ្រាម ឬការគំរាម

ធ្វើសង្គ្រាម ការគំរាមដល់សន្តិសុខជាតិ អស្ថេរភាពនយោបាយផ្ទៃក្នុង ឬភាពចលាចលទូទៅណាមួយ ដែលជាមូលហេតុនៃការធ្វើទារុណកម្ម និងការប្រព្រឹត្តឃោរឃៅ អមនុស្សធម៌ ឬទណ្ឌកម្មឯទៀតនោះឡើយ ។

***អត្ថាធិប្បាយ :***

ក- ការហាមប្រាមនេះ មានចែងនៅក្នុងបញ្ញត្តិនៃសេចក្តីប្រកាសជាសកលស្តីអំពីកិច្ចការពារបុគ្គលគ្រប់រូប ដើម្បីកុំឱ្យមានការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ដែលអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ហើយខ្លឹមសារនៃ [អំពើនេះ] គឺជាអំពើល្មើសមួយដែល ប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស អំពើល្មើសនេះនឹងត្រូវផ្តន្ទាទោសដោយសារមិនព្រមអនុវត្តតាមស្មារតីធម្មនុញ្ញសហប្រជាជាតិ ហើយវាជាការរំលោភលើសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដែលមានចែងនៅក្នុងសេចក្តីប្រកាសជា សាកលស្តីពីសិទ្ធិមនុស្ស [និងលិខិតុបករណ៍អន្តរជាតិដទៃទៀតដែលទាក់ទងនិងសិទ្ធិមនុស្ស] ។

ខ- សេចក្តីប្រកាសនេះបានឱ្យនិយមន័យនៃពាក្យទារុណកម្ម ដូចខាងក្រោមនេះ :

"...ពាក្យទារុណកម្ម សំដៅដល់អំពើទាំងឡាយណាដែលនាំឱ្យមានការឈឺចាប់ ខាងផ្លូវកាយ ឬផ្លូវចិត្ត ដែលមន្ត្រីសាធារណៈណាម្នាក់បង្កឡើងដោយចេតនា ឬដោយការញុះញង់របស់មន្ត្រីនោះ ឱ្យប្រព្រឹត្តលើជនណាម្នាក់ ក្នុងគោលបំណងឱ្យជននោះ ឬតតីយជនណាម្នាក់ ឱ្យផ្តល់ព័ត៌មាន ឬចំលើយសារភាព ការដាក់ទណ្ឌកម្មចំពោះអំពើ ដែលជននោះបានប្រព្រឹត្ត ឬសង្ស័យថាបានប្រព្រឹត្ត ឬធ្វើការបំភិតបំភ័យជននោះ ឬជនដទៃផ្សេងទៀត ។ នេះមិនបានគិតពីការឈឺចាប់ ដែលកើតមានដោយសារការដាក់ទណ្ឌកម្មស្របច្បាប់ ក្នុងកំរិតមួយដែលស្របតាមបញ្ញត្តិ ដែលមានចែងក្នុង បទដ្ឋានអប្បបរមាសំរាប់គ្រប់គ្រងអ្នកទោស " ឡើយ ។

គ- ចំពោះពាក្យថា" ការប្រព្រឹត្ត ឬការធ្វើទណ្ឌកម្មឃោឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប" មហាសន្និបាតមិនទាន់បានឱ្យអត្ថន័យពិស្តារនៅឡើយទេ ប៉ុន្តែពាក្យនេះគួរតែធ្វើការបកស្រាយយ៉ាងណា ដើម្បីពង្រីកការការពារឱ្យបានយ៉ាងទូលំទូលាយបំផុតតាមដែលអាចធ្វើបាន ប្រឆាំងរាល់ការរំលោភបំពានគ្រប់បែបយ៉ាង ខាងផ្លូវកាយ ឬ ផ្លូវចិត្ត ។

## មាត្រា ៦

មន្ត្រីប្រតិបត្តិច្បាប់គ្រប់រូបត្រូវធានារក្សាសុខភាពជនទាំងឡាយដែលឋិតក្នុងការឃុំឃាំងរបស់ខ្លួនឱ្យបានពេញលេញបរិបូរណ៍ ជាពិសេស ត្រូវចាត់វិធានការជាបន្ទាន់ ដើម្បីធានាឱ្យមានការព្យាបាលជម្ងឺ តាមការចាំបាច់ ។

***អត្ថាធិប្បាយ :***

ក- "ការព្យាបាលជម្ងឺ" សំដៅដល់ការផ្តល់សេវាផ្សេងៗដោយបុគ្គលិកផ្នែកសុខាភិបាល ក្នុងនោះមានគ្រូពេទ្យជំនាញវិជ្ជាជីវៈ និងគ្រូពេទ្យជំនួយ ដែលគ្រូពេទ្យទាំងនេះត្រូវធានាឱ្យមានជានិច្ចសំរាប់បំរើសេចក្តីត្រូវការ ។

ខ- ប្រសិនបើបុគ្គលិកផ្នែកសុខាភិបាលចាំបាច់ត្រូវចូលរួមក្នុងកិច្ចប្រតិបត្តិការជាមួយមន្ត្រីប្រតិបត្តិច្បាប់ ហើយមន្ត្រីប្រតិបត្តិច្បាប់ត្រូវពិចារណាលើការវិនិច្ឆ័យរបស់បុគ្គលផ្នែកសុខាភិបាលទាំងនេះ នៅពេលដែលគេព្យាបាលជនដែលនៅក្នុងការឃុំគ្រងរបស់ខ្លួន តាមរយៈ ឬក្នុងការពិគ្រោះយោបល់ជាមួយបុគ្គលិកផ្នែកសុខាភិបាលដែលមិនឋិតក្នុងកិច្ចប្រតិបត្តិការរបស់មន្ត្រីប្រតិបត្តិច្បាប់ ។

គ- មន្ត្រីប្រតិបត្តិច្បាប់ក៏ត្រូវធានាឱ្យមានការព្យាបាលសុខភាពដល់ជនរងគ្រោះ ដោយការរំលោភច្បាប់ ឬដោយឧបទ្ទវហេតុផ្សេងៗ ដែលកើតឡើងក្នុងពេលមានការប្រព្រឹត្តរំលោភច្បាប់ផងដែរ ។

## មាត្រា ៧

មន្ត្រីប្រតិបត្តិច្បាប់គ្រប់រូបមិនត្រូវប្រព្រឹត្តអំពើពុករលួយជាដាច់ខាត ហើយត្រូវប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយនេះឱ្យបានយ៉ាងខ្លាំងក្លា ។

***អត្ថាធិប្បាយ :***

ក- អំពើពុករលួយ ក៏ដូចគ្នានឹងការបំពានច្បាប់របស់រដ្ឋពីសំណាក់អាជ្ញាធរដែរ ហើយអំពើបែបនេះជាអំពើដែលផ្ទុយពីកាតព្វកិច្ចរបស់មន្ត្រីប្រតិបត្តិច្បាប់ ។ មន្ត្រីប្រតិបត្តិច្បាប់ដែលប្រព្រឹត្តអំពើពុករលួយត្រូវទទួលការផ្តន្ទាទោសតាមច្បាប់ ដោយគ្មានការយោគយល់ឡើយ ព្រោះថារដ្ឋាភិបាលពុំអាចយកច្បាប់ មកគ្រប់គ្រងលើប្រជាពលរដ្ឋបានទេ ប្រសិនបើ រដ្ឋាភិបាលមិនអាចអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវទៅលើភ្នាក់ងារ ឬស្ថាប័នរបស់ខ្លួន ។

ខ- និយមន័យនៃពាក្យ "អំពើពុករលួយ" ត្រូវតែមានចែងក្នុងច្បាប់ជាតិ ។ ការរួមគំនិតប្រព្រឹត្តអំពើសូកប៉ាន់ផ្សេងៗ គឺជាបទល្មើសពុករលួយ។ នៅពេលកំពុងបំពេញភារកិច្ចក្នុងនាម ជាមន្ត្រីប្រតិបត្តិច្បាប់ បើមានការ

ព្រងើយកន្តើយមិនបង្ក្រាបអំពើសូកប៉ាន់ឱ្យបានច្បាស់លាស់ទេ មន្ត្រីប្រតិបត្តិច្បាប់ ត្រូវចាត់ទុកថា បានឃុបឃិតក្នុងអំពើពុករលួយដែរ ។ ការទទួលអំណោយ (ជាវត្ថុ ឬជាប្រាក់) រង្វាន់លើកទឹកចិត្តផ្សេងៗ ការសន្យានានា ដែលមិនសមស្របទៅនឹងវិន័យត្រូវចាត់ទុកថាជាបទល្មើសពុករលួយ ។

គ- ពាក្យថា "អំពើពុករលួយ" ដែលបានចែងក្នុងប្រយោគខាងលើ ត្រូវរាប់បញ្ចូលផងដែរនូវឆន្ទៈ ឬការប៉ុនប៉ងទទួលសំណូកគ្រប់ប្រភេទ ។

## មាត្រា ៨

មន្ត្រីប្រតិបត្តិច្បាប់គ្រប់ស្រទាប់ជាន់ថ្នាក់ ត្រូវគោរពតាមច្បាប់ និងបទវិន័យនេះ ហើយត្រូវទប់ស្កាត់ និងប្រឆាំងយ៉ាងខ្លាំងក្លាបំផុតចំពោះអំពើទាំងឡាយណា ដែលបំពាន ឬប៉ះពាល់ដល់ច្បាប់ និងបទវិន័យនេះ ។

មន្ត្រីប្រតិបត្តិច្បាប់ ដែលដឹងប្រាកដថា មានជនណាម្នាក់បានរំលោភ ឬប្រុងនឹងរំលោភលើបទវិន័យនេះ ត្រូវតែរាយការណ៍អំពីរឿងនេះទៅអាជ្ញាធរថ្នាក់លើ ហើយប្រសិនជាចាំបាច់ត្រូវរាយការណ៍ទៅស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ចដទៃទៀត ដែលមានអំណាចពិនិត្យ ឬដោះស្រាយ ។

***អត្ថាធិប្បាយ :***

ក- គេត្រូវតែគោរពតាមបទវិន័យនេះភ្លាម កាលណាបទវិន័យនេះបានត្រូវគេបញ្ចូលទៅក្នុងក្របខ័ណ្ឌច្បាប់នីតិបញ្ញត្តិ និងនីតិប្រតិបត្តិ ។ ប៉ុន្តែនៅប្រទេសខ្លះច្បាប់នីតិបញ្ញត្តិ ឬនីតិប្រតិបត្តិរបស់គេ មានលក្ខណៈតឹងរឹងជាងបទវិន័យបច្ចុប្បន្ននេះទៅទៀត ។ ក្នុងករណីបែបនេះ មន្ត្រីប្រតិបត្តិច្បាប់ត្រូវតែគោរពតាមច្បាប់ដែលតឹងរឹងនោះ ។

ខ- មាត្រានេះ សំដៅធ្វើការថ្លឹងថ្លែងរវាងសេចក្តីត្រូវការឱ្យមានការគោលសំខាន់ពីរ គោលសំខាន់ទី១ គឺការរក្សា និងការពង្រឹងវិន័យផ្ទៃក្នុងរបស់ស្ថាប័ន ដើម្បីជាប្រយោជន៍ដ៏ទូលំទូលាយដល់សន្តិសុខសាធារណៈ ។ គោលសំខាន់ទី២ គឺការបង្ការ និងការការពារកុំឱ្យមានអំពើរំលោភលើសិទ្ធិមនុស្សជាមូលដ្ឋាន ។ បើមានការរំលោភច្បាប់ មន្ត្រីប្រតិបត្តិច្បាប់ត្រូវធ្វើសេចក្តីរាយការណ៍ជូនទៅនាយចៅហ្វាយតាមលំដាប់ឋានានុក្រម ។ ដរាបណាស្ថាប័នរបស់ខ្លួនបានប្រើគ្រប់មធ្យោបាយហើយនៅតែគ្មានប្រសិទ្ធិភាព ដរាបនោះមន្ត្រីប្រតិបត្តិច្បាប់ អាចរាយការណ៍អំពីរឿងរំលោភច្បាប់នេះ ទៅស្ថាប័នមានសមត្ថកិច្ចដទៃទៀត ។ ក្នុងការធ្វើសេចក្តីរាយការណ៍អំពីការរំលោភលើបទវិន័យ ឬអំពីគំរោងផែនការ នៃការប្រព្រឹត្តអំពើពុករលួយណាមួយ អ្នករាយការណ៍ (មន្ត្រីប្រតិបត្តិច្បាប់) មិនត្រូវបាន ទទួលទណ្ឌកម្ម ឬដាក់វិន័យរដ្ឋបាលណាមួយពីស្ថាប័នរបស់ខ្លួនឡើយ ។

គ- ពាក្យថា "អាជ្ញាធរមានសមត្ថកិច្ច ឬអង្គការរដ្ឋដែលមានអំណាចពិនិត្យ និងដោះស្រាយ" សំដៅដល់អាជ្ញាធរ ឬអង្គការរដ្ឋដែលស្ថិតនៅក្នុងរង្វង់នៃច្បាប់ជាតិ ទោះជាអាជ្ញាធរ ឬអង្គការរដ្ឋនោះនៅក្នុង ឬឯករាជ្យពីស្ថាប័នប្រតិបត្តិច្បាប់នោះក៏ដោយ ដែលមានអំណាចតាមលក្ខខណ្ឌអំណាចតាមទម្លាប់ ឬអំណាចផ្សេងៗទៀត ក្នុងការពិនិត្យលើបណ្តឹងសារទុក្ខ ឬបណ្តឹងផ្សេងទៀតអំពីការរំលោភបំពានច្បាប់នៅក្នុងរង្វង់ព្រំដែននៃបទវិន័យនេះ ។

ឃ- នៅប្រទេសខ្លះ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានគ្រប់បែបយ៉ាង ត្រូវបានគេចាត់ទុកថាបានបំពេញភារកិច្ចក្នុងការពិនិត្យសើរើពាក្យបណ្តឹងនានា ប្រហាក់ប្រហែលគ្នាទៅនឹងភារកិច្ចដែលបានរៀបរាប់នៅក្នុងវគ្គ (គ) ខាងលើ ។

ង- ដើម្បីទាក់ទាញមតិសាធារណជន ឱ្យចេះឈឺឆ្អាលក្នុងរឿងរំលោភច្បាប់នេះ ភ្នាក់ងារក្រសួងការពារច្បាប់អាចផ្សព្វផ្សាយតាមរយៈវិទ្យុ, ទូរទស្សន៍, ភាពយន្ត, ល្ខោន, ទស្សនាវដ្តី ឬកាសែតក៏បាន ឱ្យតែគេអាចបញ្ជាក់ហេតុផលថា គេបានអនុលោមទៅតាមច្បាប់ទម្លាប់របស់ប្រទេសគេ និងគោរពតាមបញ្ញត្តិនៃមាត្រាទី៤ ក្នុងបទវិន័យនេះ ។ ប៉ុន្តែការប្រើតាមមធ្យោបាយខាងលើនេះ អាចប្រើបានតែក្នុង ដំណាក់ការចុងក្រោយបំផុតប៉ុណ្ណោះ ប្រសិនបើគ្រប់មធ្យោបាយឯទៀតដែលគេបានប្រើរួចមកហើយនោះ ពុំបានសំរេចដូចបំណង ។

ច- ភ្នាក់ងារក្រសួងការពារច្បាប់ទាំងឡាយណា ដែលបានគោរពច្បាប់នៃបទវិន័យនេះ តែងតែបានទទួលនូវការគោរពស្ងើចសរសើរ, ការគាំទ្រ, ព្រមទាំងការរួមសហប្រតិបត្តិការពីសំណាក់សហគមន៍, ពីសំណាក់ស្ថាប័នអនុវត្តន៍ច្បាប់ និងពីសំណាក់អ្នកដែលមានអាជីពក្នុងវិស័យប្រតិបត្តិច្បាប់ ។

~~~~~~~~~
~~~~~~~~~